អាជ្ញាធរសវនកម្មជាតិ
លេខ: ០០៧/១៧ អសជ/ស.ទ.ស

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសបេក្ខជនឱ្យចូលបម្រើការងារក្នុងក្របខណ្ឌអាជ្ញាធរសវនកម្មជាតិ សម្រាប់ឆ្នាំ២០១៧

អាជ្ញាធរសវនកម្មជាតិសូមជូនដំណឹងដល់និស្សិត និងមន្ត្រីរាជការទូទៅឱ្យបានជ្រាបថា អាជ្ញាធរសវនកម្មជាតិនឹងធ្វើការជ្រើសរើសបេក្ខជន-បេក្ខនារី ជានិស្សិត និងមន្ត្រីរាជការទូទៅចំនួន **៥៥** កន្លែង ឲ្យចូលបម្រើការងារនៅអាជ្ញាធរសវនកម្មជាតិសម្រាប់ឆ្នាំ២០១៧ តាមរយៈការប្រឡងប្រជែងដោយវិញ្ញាសាសរសេរ និងវិញ្ញាសាផ្ទាល់មាត់ ៖

**ក. លក្ខខណ្ឌនៃការជ្រើសរើស៖**

- សញ្ជាតិខ្មែរ
- មានកម្រិតសញ្ញាបត្របរិញ្ញាបត្រឡើងទៅដែលពាក់ព័ន្ធច្បាប់ ឬសេដ្ឋកិច្ច ឬព័ត៌មានវិទ្យា
- មានអាយុមិនលើសពី៣៥ឆ្នាំ គិតត្រឹមថ្ងៃប្រឡង ករណីមានសញ្ញាបត្របរិញ្ញាបត្រ
- មានអាយុមិនលើសពី៤០ឆ្នាំ គិតត្រឹមថ្ងៃប្រឡង ករណីមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់
- បានលើកលែងលក្ខខណ្ឌអាយុ ចំពោះបេក្ខជនជាមន្ត្រីរាជការទូទៅ និងបេក្ខជនជានិស្សិតដែលមានសញ្ញាបត្រថ្នាក់បណ្ឌិតឡើងទៅ

**ខ. សំណុំបែបបទនៃការចុះឈ្មោះប្រឡង៖**

| | |
|---|---|
| – ពាក្យសុំចុះឈ្មោះប្រឡង | ចំនួន ០១ ច្បាប់ |
| – សេចក្តីចម្លងសញ្ញាបត្រដោយមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ | ចំនួន ០១ ច្បាប់ |
| – ជីវប្រវត្តិសង្ខេបមានបិទរូបថតថ្មី ៤x៦ | ចំនួន ០១ ច្បាប់ |
| – កិច្ចសន្យាបម្រើការងារ | ចំនួន ០១ ច្បាប់ |
| – សលាកបត្រឯកត្តជនមានបិទរូបថតថ្មី ៤x៦ | ចំនួន ០១ ច្បាប់ |
| – រូបថតថ្មី ៤x៦ | ចំនួន ០២ សន្លឹក |
| – បង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡង | ចំនួន ០១ ច្បាប់ |
| – អត្តសញ្ញាណប័ណ្ណ ឬសេចក្តីចម្លងសំបុត្រកំណើត | ចំនួន ០១ ច្បាប់ |
| – វិញ្ញាបនបត្ររដ្ឋបាល (បេក្ខជនជាមន្ត្រីរាជការ) | ចំនួន ០១ ច្បាប់ |
| – ព្រឹត្តិបត្រថ្កោលទោស (ក្រោយពេលប្រឡងជាប់) | ចំនួន ០១ ច្បាប់ |
| – លិខិតបញ្ជាក់សុខភាព(ក្រោយពេលប្រឡងជាប់) | ចំនួន ០១ ច្បាប់ |

**គ. រយៈពេលនៃការទទួលសំណុំបែបបទប្រឡង ៖**

- ចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងនេះរហូតដល់ថ្ងៃទី២៩ ខែកញ្ញា **ឆ្នាំ២០១៧**
- ចំពោះសំណុំបែបបទនៃការចុះឈ្មោះប្រឡង អាចមកទទួលដោយឥតគិតថ្លៃ នៅទីស្តីការអាជ្ញាធរសវនកម្មជាតិ ដែលមានអាសយដ្ឋាន អគារលេខ៥ ផ្លូវឌួងងៀប៣ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌ

សែនសុខ រាជធានីភ្នំពេញ (នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុជាន់ផ្ទាល់ដី, ការិយាល័យរដ្ឋបាល និងការិយាល័យបុគ្គលិក) ឬអាចទាញយកតាមអាសយដ្ឋានគេហទំព័រ www.naa.gov.kh ដើម្បីទាញយកមកបំពេញ រួចមកដាក់នៅទីស្តីការអាជ្ញាធរសវនកម្មជាតិ រៀងរាល់ម៉ោងធ្វើការ។

**ឃ. មុខវិជ្ជាប្រឡង**

**វិញ្ញាសាសរសេរ**

- ចំណេះដឹងទូទៅពាក់ព័ន្ធសេដ្ឋកិច្ច សវនកម្ម គណនេយ្យ ច្បាប់
- ជំនាញច្បាប់ ឬជំនាញសេដ្ឋកិច្ច ឬជំនាញព័ត៌មានវិទ្យា
- ភាសាអង់គ្លេស

**វិញ្ញាសាផ្ទាល់មាត់ និងអនុវត្តកុំព្យូទ័រ**

- ចំណេះដឹងទូទៅ
- ជំនាញច្បាប់ ឬជំនាញសេដ្ឋកិច្ច ឬជំនាញព័ត៌មានវិទ្យា
- ភាសាអង់គ្លេស
- កុំព្យូទ័រ

ចំពោះកាលបរិច្ឆេទនៃការប្រឡង មណ្ឌលប្រឡង ឈ្មោះ កាលវិភាគ និងការណែនាំផ្សេងៗដល់បេក្ខជន បេក្ខនារីប្រឡង នឹងជូនដំណឹងនៅពេលក្រោយ។

ព័ត៌មានលម្អិតបន្ថែមផ្សេងទៀត សូមមកទំនាក់ទំនងជាមួយនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុជាន់ផ្ទាល់ដី រៀងរាល់ម៉ោងធ្វើការ។

អាជ្ញាធរសវនកម្មជាតិសូមរក្សាសិទ្ធិកែប្រែខ្លឹមសារណាមួយនៃសេចក្តីជូនដំណឹងនេះក្នុងករណីមានការចាំបាច់។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៧

**ជ-គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារនៅអាជ្ញាធរសវនកម្មជាតិ**

**ប្រធាន**

**សោម គីមសួគ៌**